# <u>ចំណុចសន្ទរកថា</u>

# ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋលេខាធិការ

# និងជាប្រធានគណៈកម្មការអនុវត្តន៍

### រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ២០១១ ក្រសួងពាណិជ្ជកម្ម

<u>ក្រោយពី Light Supervision Mission ពី ២៨ មិនា - មេសា ០៤ ឆ្នាំ២០១១</u>

- **យើងបានធ្វើការចំណាយរហូតដល់ ៤៥.៥% ក្នុងត្រីមាសទី២ (ពីខែមេសាដល់ ខែមិថុនា) បើធៀបនិងទឹក ប្រាក់ $១,១៧៣,២៥៩ ឬស្មើនឹង $៥៣៤,២៦៨។**
- ប្រសិនបើពិនិត្យលើគម្រោងតាមសមាសភាពនីមួយៗរហូតមកដល់ថ្ងៃនេះ ក្រោមកម្មវិធី TDSP យើងអនុវត្តន៍ឱ្យបាន ៖
    - ការរៀបចំគោលនយោបាយពាណិជ្ជកម្ម និងការអនុវត្ត (Trade Policy Formulation and Implementation) បានចំណាយអស់ទឹកប្រាក់សរុប ចំនួន $២២៩.៧៣១ ក្នុងត្រីមាសទី២ នេះ
    - ការអនុវត្តការត្រួតពិនិត្យ (Monitoring Performance) មិនទាន់មានសកម្មភាពចំណាយណាមួយនៅឡើយរហូតមកដល់ត្រីមាសទី២ នេះ
    - ការពង្រឹកសមត្ថភាពស្ថាប័ន និងធនធានមនុស្ស (Strengthen Institutional and Human Capacity) ការចំណាយមានចំនួន $៨០.៩២៨ ក្នុងត្រីមាសទី២ នេះ
    - ការគាំទ្រដល់ការអនុវត្តនកម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្ម (Implementation Support to TDSP) ការចំណាយមានចំនួន $២២៣.៦០៩ ក្នុងត្រីមាសទី២ នេះ

<u>សកម្មភាពនទាំងនេះសឱ្យឃើញថា ការអនុវត្តកម្មវិធី</u> TDSP មានសន្ទុះ <u>លឿនជាងមុនលើការអនុវត្តន៍របស់ខ្លួន បើប្រៀបធៀបទៅនឹងត្រីមាសទី២ កាលពីឆ្នាំ ២០១០</u> កន្លងទៅ។

ជាបន្តបន្ទាប់ <u>គណៈកម្មការអនុវត្តន៍បានសម្រេចគម្រោងយុទ្ធសាស្ត្រចំនួន ០១</u> ក្នុងចំណោមគម្រោងយុទ្ធសាស្ត្រចំនួន ១០ ខាងលើ កាលពីថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០១១ កន្លងទៅ។ ចំណែកឯផែនទីបង្ហាញផ្លូវឬ Roadmap យើងបានសម្រេចឱ្យអនុវត្តន៍ចំនួន១ គឺ Roadmap of Pillar 3 តែនៅមាន Roadmap ចំនួនពីរទៀតមិនទាន់បានបញ្ចប់នៅឡើយ ហើយនាព្រឹកនេះសង្ឃឹមថាតំណាង Roadmap ទាំងពីរនឹងធ្វើបច្ចុប្បន្នភាពជូនអង្គប្រជុំជុំវិញវឌ្ឍនៈភាពនៃការងារនេះ។

គណៈកម្មការអនុវត្តន៍ នាព្រឹកនេះគ្រោងនិងដាក់ជូនអង្គប្រជុំនូវគម្រោងយុទ្ធសាស្រ្តចំនួន ២ ដែលបានស្នើសុំដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីសុំការសម្រេចពីសមាជិកនិងសមាជិការរបស់អង្គប្រជុំ។ លោក **ឈៀង ពេជ្រ** ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងជានាយកគម្រោង TDSP និងធ្វើបទបង្ហាញជូនអង្គប្រជុំក្នុងពេលបន្តិចទៀតនេះ។

ជាទីបញ្ចប់ ដើម្បីកុំឱ្យខាតពេលខ្ញុំសូមប្រគល់តួនាទីនេះជូនលោក លោក ឈៀង ពេជ្រ ធ្វើបទអន្តរាគមន៍នូវរបាយការណ៍វឌ្ឍនៈភាពនៃការអនុវត្តកម្មវិធី TDSP ព្រមទាំងបង្ហាញនូវសំណើនានាជូនអង្គប្រជុំ ដូចមានចែងក្នុងកម្មវិធីនាព្រឹកនេះ ដូចតទៅ។

សូមអរគុណ។